【កំណែឆ្នាំ2025】

# ឧទាហរណ៍ល្អប្រសើរនៃការទទួលជនបរទេសជំនាញជាក់លាក់សម្រាប់វិស័យកសិកម្ម

## ក្រុមហ៊ុន SHIRAMIZU Farm Co., Ltd.

~ ជំនាញជាក់លាក់ចំនួន20នាក់ និងជំនាញកម្រិត2 ដល់ទៅ3នាក់

តាមរយៈការគ្រប់គ្រងដំណើការផែនការ6ឆ្នាំ និងការពិភាក្សាគ្នា ~

| ព័ត៌មានមូលដ្ឋាន | |
|---|---|
| ទីតាំង៖ ឃុំយ៉ាអេសេ ស្រុកសិម៉ាជិរិ ខេត្តអូគិណាវ៉ា<br>ក្រុមហ៊ុន SHIRAMIZU Farm Co., Ltd. (ដែលមានប្រវត្តិជាង 100ឆ្នាំ និងបានក្លាយជាក្រុមហ៊ុនចាប់ពីឆ្នាំ2018មក)<br>ប្រភេទដាំដុះ៖ ផ្តោតលើផ្កាកុហ្គិគឺ ក្នុងរដូវស្លឹកឈើជ្រុះ និងរដូវរងា (80%) និងពោតបារាំងជាដើម ក្នុងរដូវស្លឹកឈើលាស់ និងរដូវក្តៅ (20%) ផ្កាកុហ្គិគឺប្រហែល3លានទង<br>ផ្ទៃក្រឡាដាំដុះ៖ ដីវាលចំនួន12ហិកតា<br>សមាសភាពបុគ្គលិក៖ ជនជាតិជប៉ុន (គ្រប់គ្រងរដ្ឋបាល) 1នាក់ + ជនបរទេសជំនាញជាក់លាក់ 20នាក់ (ជនជាតិឥណ្ឌូ |  |

| | |
|---|---|
| នេស៊ីទាំងអស់)<br>ជំនាញជាក់លាក់កម្រិត2 ចំនួន3នាក់ ⇒ ប្រឡងជាប់ចំនួន3នាក់ (ក្នុងនោះមានម្នាក់ ដែលបានប្តូរគុណសម្បត្តិស្នាក់នៅ) | |

| |
|---|
| កិច្ចផ្តួចផ្តើមពិសេសដោយឡែក (ការបង្កើនប្រសិទ្ធភាពការងារ និង ការបង្កើតបរិយាកាសដែលងាយធ្វើការងារ)<br>① ដោយការពុះពារគ្រប់គ្រងដំណើរការដែលមានផែនការ ខ្លឹមសារការងារកាន់តែមានប្រសិទ្ធភាព ការលក់មានការកើនឡើង ហើយដោយហេតុនេះ ជនបរទេសជំនាញជាក់លាក់ក៏មានការកើនឡើងផងដែរ<br>② ពិនិត្យឡើងវិញដោយភាពបត់បែននូវការបែងចែកបុគ្គលិក តាមរយៈការនិយាយគ្នារវាងនិយោជកនិងនិយោជិត។ ជ្រើសតាំងអ្នកដឹកនាំចំនួន2នាក់ ពីជនបរទេសជំនាញជាក់លាក់ និងផ្តោះទៅបរិយាកាសកន្លែងធ្វើការដែលបង្កលក្ខណៈឲ្យមានភាពឯករាជ្យ |
| <u>1. ធនធានមកពីបរទេសមានការកើនឡើង តាមរយៈការពុះពារគ្រប់គ្រងដំណើរការ6ឆ្នាំ និងការនិយាយគ្នា</u><br>(1) កិច្ចផ្តួចផ្តើមដែលបានធ្វើរយៈពេល6ឆ្នាំ គំនិត និងវិធានការជាក់លាក់<br>① ពេលដឹងអំពីការដាក់ឲ្យដំណើរការប្រព័ន្ធជំនាញជាក់លាក់ យើងបានចាប់ផ្តើមទទួល |

ជនបរទេសជំនាញជាក់លាក់យ៉ាងឆាប់រហ័សតាមដែលអាចធ្វើបាន។ តាំងពីរើសចូលដំបូងៗ យើងបានប្រាប់ពួកគេថា "យើងចង់ឲ្យអ្នកគិតទុកជាមុននៅពេលធ្វើការ" ហើយនៅពេលបច្ចុប្បន្ននេះ យើងបានជ្រើសតាំងជនបរទេសជំនាញជាក់លាក់ចំនួន2នាក់ ដែលមានបទពិសោធន៍ច្រើន ឲ្យធ្វើជាអ្នកដឹកនាំ។ ការបញ្ជាពីអ្នកតំណាងក្រុមហ៊ុន ត្រូវបានបញ្ជូនបន្តទាំងជាភាសាជប៉ុន និងភាសាកំណើត ហើយយើងបានរៀបចំប្រព័ន្ធមួយដែលបង្កើនប្រសិទ្ធភាពកិច្ចការផ្សេងៗ។

② ក្រោយពីទទួលបានសំណើពីជនបរទេសជំនាញជាក់លាក់ យើងបានបង្កើតកាលវិភាគដែលសមាជិកទាំងអស់អាចពិនិត្យមើលបាន។ យើងមានអារម្មណ៍ថា នៅពេលនេះជនបរទេសជំនាញជាក់លាក់ក៏អាចវិនិច្ឆ័យពីភាពមមាញឹកជាដើមបានដែរ ហើយពួកគេអាចធ្វើការងារបានយ៉ាងមានតុល្យភាព។ លើសពីនេះ ដោយផ្អែកលើការនិយាយគ្នា យើងក៏អនុញ្ញាតឲ្យពួកគេត្រលប់ទៅប្រទេសកំណើតវិញបណ្ដោះអាសន្នក្នុងរយៈពេលយូរ (2-6 ខែ) ដើម្បីរៀបការ ឬមានកូន ជាដើម ហើយអនុញ្ញាតឲ្យជនបរទេសជំនាញជាក់លាក់សម្រេចចិត្តដោយឯករាជ្យ អំពីចំនួនមនុស្ស និងពេលវេលាដែលត្រលប់ទៅប្រទេសកំណើតវិញបណ្ដោះអាសន្ន។

③ យើងក៏បានឃើញថាមានធនធានមនុស្សផ្សេងក្រៅពីអ្នកដឹកនាំ ដែលអាចគ្រប់គ្រងម៉ាស៊ីនភ្ជួររាស់ និងម៉ាស៊ីនរើសញែកបាន ហើយយើងមានអារម្មណ៍ថា វាបង្ហាញពីការលេចចេញនូវភាពឯករាជ្យ។  យើងក៏បានទទួលយកសំណើរបស់ជនបរទេសជំនាញជាក់លាក់ និងបានកែលម្អប្រព័ន្ធរៀបចំក្រុម និងចំនួនមនុស្សផងដែរ ហើយយើងមាន

អារម្មណ៍ថា យើងបានបង្កើតបរិយាកាសដ៏ល្អមួយ។

④ ខាងអ្នកគ្រប់គ្រងដំណើរការ តែងតែរិះគិតថា "តើធ្វើបែបណាដើម្បីឲ្យកាន់តែងាយស្រួលធ្វើការងារ?" ហើយជាលទ្ធផល ចំនួនជនបរទេសជំនាញជាក់លាក់ដែលចង់ធ្វើការឲ្យក្រុមហ៊ុនយើង មានការកើនឡើង។ ដោយសារមានជនបរទេសជំនាញជាក់លាក់ដែលធ្វើការឲ្យយើងក្នុងរយៈពេលយូរ យើងអាចកសាងប្រព័ន្ធផលិតកម្មដែលមានស្ថិរភាព ហើយការលក់បាន មានការកើនឡើងប្រហែល 2. 6 ដង បើប្រៀបធៀបទៅនឹង6ឆ្នាំមុន។ ការពង្រីកទ្រង់ទ្រាយនៃការគ្រប់គ្រងដំណើរការ ក៏ជាហេតុនាំឲ្យមានការកើនឡើងនៃចំនួនបុគ្គលិកជាជនបរទេសជំនាញជាក់លាក់ផងដែរ។

(2) ប្រាក់ឈ្នួលគោល លើសពីប្រាក់ឈ្នួលអប្បបរមា ចំនួន100យ៉េនក្នុងមួយម៉ោង ហើយយើងមិនមានប្រព័ន្ធឡើងប្រាក់ឈ្នួលតាមរយៈការវាយតម្លៃទេ ប៉ុន្តែយើងឆ្លុះបញ្ចាំងវាទៅក្នុងប្រាក់រង្វាន់។

① ទាក់ទងនឹងការវាយតម្លៃធនធានមនុស្ស បុគ្គលិកជាច្រើនបានសម្ដែងមតិដូចជា "ទាំងអស់គ្នា សុទ្ធតែខំប្រឹងធ្វើការ" និង "មិនចង់ឲ្យធ្វើបែបនេះទេ"។ យើងមានអារម្មណ៍ថាការវាយតម្លៃធនធានមនុស្សដោយដៃគូដែលស្គាល់ចិត្តថ្លើមគ្នា អាចនឹងបំបែកបំបាក់កន្លែងធ្វើការបាន ហើយយើងពេញចិត្តស្ថានភាពដែលគ្រប់គ្នាទទួលបានការវាយតម្លៃខ្ពស់ ដូច្នេះយើងមិនធ្វើការវាយតម្លៃធនធានមនុស្សជាលក្ខណៈបុគ្គលទេ។

② ដោយសារតែពេលខ្លះបុគ្គលិកសម្រេចកិច្ចការបានច្រើនជាងការរំពឹងទុករបស់ខាង

គ្រប់គ្រងដំណើរការទៅទៀត យើងមានអារម្មណ៍ថាការបង្កើតបរិយាកាសដែលងាយធ្វើការងារ នឹងផ្តល់ផលវិជ្ជមាន ដូច្នេះយើងផ្តល់អត្ថប្រយោជន៍ដល់បុគ្គលិកដែលធ្វើការយូរ ដោយបន្ថែមតាមឆ្នាំនៃការបម្រើការងារ និងប្រាក់រង្វាន់សម្រាប់អ្នកបន្តធ្វើការយូរឆ្នាំ។ អ្នកដឹកនាំ ត្រូវបានសម្រេចរើសដោយខាងគ្រប់គ្រងដំណើរការ ដោយគិតគូរលើភាពទុកចិត្តបាននៃកិច្ចការ និងការយល់ដឹងភាសាជប៉ុន ហើយយើងផ្តល់ប្រាក់ឧបត្ថម្ភមុខតំណែង។

③ ការឆ្លុះបញ្ចាំងទៅក្នុងប្រាក់ឈ្នួលម៉ោង និងការទទួលបានប្រាក់ឈ្នួលសមរម្យសម្រាប់ម៉ោងធ្វើការ គឺមានភាពសមស្របនឹងការគិតរបស់ជនបរទេសជំនាញជាក់លាក់ ដូច្នេះយើងបានកំណត់ប្រាក់ឈ្នួលម៉ោងប្រហែល100យ៉េនលើសពីប្រាក់ឈ្នួលអប្បបរមាដែលមានន័យថាយើងបង់ប្រាក់ច្រើនជាងប្រាក់ឈ្នួលអប្បបរមា។

## 2. ការរីកចម្រើនក្នុងអាជីពជាដើមរបស់ជនបរទេសជំនាញជាក់លាក់

① ទាក់ទងនឹងការប្រឡងជំនាញជាក់លាក់កម្រិត2 ខាងគ្រប់គ្រងដំណើរការ ធ្វើការលើកទឹកចិត្តការប្រឡងជាប់ ដោយផ្តល់ប្រាក់អបអរសាទរ ដល់អ្នកដែលបានប្រឡងជាប់។ យើងស្វាគមន៍ជំនាញជាក់លាក់កម្រិត2 ពីព្រោះវាធ្វើឲ្យការបណ្តុះបណ្តាលកាន់តែងាយស្រួល ដោយសារចំនួនបុគ្គលិកជើងចាស់មានកាន់តែច្រើន។

ដោយសារជំនាញជាក់លាក់កម្រិត2 នឹងអាចឲ្យសមាជិកគ្រួសារមកនៅប្រទេសជប៉ុនបាន ដូច្នេះវាទំនងជាពិបាកបើធ្វើដូចជំនាញកម្រិត1។ បើនៅពេលអនាគត ជំនាញ

ជាក់លាក់កម្រិត2 អាចឲ្យសមាជិកគ្រួសារមកនៅប្រទេសជប៉ុនបាន យើងនឹងផ្តល់ការ

គាំទ្រ និងនិយាយគ្នាទៅតាមការចាំបាច់។

② ខាងនិយោជក ដាច់ខាតត្រូវតែផ្តល់ការគាំទ្រសម្រាប់ការប្រឡងជំនាញកម្រិត2។ យើងផ្តល់ការគាំទ្រដោយជួយរកចម្លើយនៅពេលជនបរទេសជំនាញជាក់លាក់មិនយល់ត្រង់ណា។ ជាលទ្ធផល យើងមានអ្នកប្រឡងជាប់ចំនួន3នាក់។

③ ចាប់ពីពេលនេះតទៅ យើងកំពុងពិចារណាសាងសង់អន្តេវាសិកដ្ឋានផ្ទាល់ខ្លួនរបស់យើង ដើម្បីកែលម្អបរិយាកាសការងារបន្ថែមទៀត។ យើងមានគម្រោងស្តាប់យោបល់របស់ជនបរទេសជំនាញជាក់លាក់ និងគិតគូរយ៉ាងណាឲ្យបរិក្ខារមានភាពសមស្របនឹងវប្បធម៌របស់ពួកគេ។

④ តាមរយៈការបង្កើតបរិយាកាសមួយដែលងាយធ្វើការងារសម្រាប់ជនបរទេសជំនាញជាក់លាក់ យើងនឹងអាចជួលបុគ្គលិកបានកាន់តែច្រើន ហើយយើងបានឮដំណឹងថានៅប្រទេសឥណ្ឌូនេស៊ី ក៏មានមនុស្សជាច្រើនដែលចង់ធ្វើការឲ្យក្រុមហ៊ុនយើងដែរ។ លើសពីនេះ អ្នកខ្លះដែលបានឈប់ពីក្រុមហ៊ុនម្តងហើយ និងបានត្រលប់ទៅប្រទេសកំណើតវិញ ក៏ចង់ត្រលប់មកធ្វើការឲ្យយើងម្តងទៀតដែរ។

※ កិច្ចសម្ភាសជាមួយធនធានមនុស្សមកពីបរទេស

(លោក ស៊ូរីអាណា ដែលយកបានជំនាញជាក់លាក់កម្រិត2)



(លោក ដេវ៉ាំ ជំនាញជាក់លាក់កម្រិត1 (ជាប់ការប្រឡងជំនាញកម្រិត2 និងជាអ្នកគ្រប់គ្រងការងារ)



① ហេតុអ្វីបានជាអ្នកមកធ្វើការនៅប្រទេសជប៉ុន?

ស៊ូរីអាណា៖ នៅប្រទេសកំណើតរបស់ខ្ញុំ មិនសូវមានការងារច្រើនទេ។ ហើយក៏ដោយសារប្រទេសជប៉ុនគឺជាប្រទេសដែលស្អាត និងមានសុវត្ថិភាពផងដែរ។ នៅក្នុងប្រទេសជប៉ុន ខ្ញុំបានធ្វើការ3ឆ្នាំក្នុងទម្រង់ជាកម្មសិក្សាហ្វឹកហ្វឺនជំនាញ និងធ្វើការបាន7ឆ្នាំហើយក្នុងទម្រង់ជាជំនាញជាក់លាក់។

ដេវ៉ាំ៖ នៅប្រទេសកំណើតរបស់ខ្ញុំ ខ្ញុំបានជួយឪពុកម្ដាយរបស់ខ្ញុំធ្វើកសិកម្ម ហើយខ្ញុំបានធ្វើការក្នុងទម្រង់ជាកម្មសិក្សាហ្វឹកហ្វឺនជំនាញ នៅក្នុងខេត្តអ៊ិបារ៉ាគិ។ ប្រាក់ចំណូលនៅក្នុង

ប្រទេសជប៉ុន លើសច្រើនពីនៅក្នុងប្រទេសកំណើតរបស់ខ្ញុំ ហើយខ្ញុំមកធ្វើការដើម្បីសន្សំប្រាក់។

② សូមរៀបរាប់អំពីការងាររបស់អ្នក។ តើកន្លែងធ្វើការរបស់អ្នក មានបរិយាកាសងាយស្រួលធ្វើការងារដែរឬទេ? តើចំណុចណាដែលអ្នកគិតថាការងាររបស់អ្នកមានន័យ?

ស៊ូរីអាណា៖ ចំពោះការដាំដុះផ្កាកុហ្គិគី និងការងារពោតបារាំង ពេលខ្លះក៏វាពិបាកខ្លាំងដែរ ដូចជាការធ្វើគម្របបាំងដី និងការបញ្ជាប្រតិបត្តិការគោយន្តជាដើម ប៉ុន្តែពេលនេះ ខ្ញុំស៊ាំហើយ និងសប្បាយនឹងការធ្វើការងារ។

ដេវ៉ា៖ ឥឡូវនេះ ខ្ញុំកំពុងរៀបចំត្រៀមសម្រាប់ដាំដុះផ្កាកុហ្គិគី ហើយចាប់ពីចុងខែវិច្ឆិការហូតដល់ខែឧសភា ខ្ញុំនឹងធ្វើការងារប្រមូលផល។ សម្រាប់ការគ្រប់គ្រងការដាំដុះ និងការងារផ្សេងៗ ខ្ញុំក៏ជាអ្នកចេញបញ្ជាផងដែរ ក្នុងនាមជាអ្នកទទួលខុសត្រូវការងារ។

③ នៅក្នុងការងារ តើមានរឿងអ្វីដែលអ្នកប្រុងប្រយ័ត្នជាពិសេសដែរឬទេ?

ស៊ូរីអាណា៖ ជាពិសេសនៅអំឡុងពេលក្តៅខ្លាំងនៃរដូវក្តៅ ខ្ញុំស្លៀកពាក់សម្លៀកបំពាក់ការងារដែលមានភ្ជាប់កង្ហារ។ លើសពីនេះ ខ្ញុំក៏ព្យាយាមប្តូរពីបណ្ណបើកបរបរទេសមកជាបណ្ណបើកបរជប៉ុនដែរ ប៉ុន្តែវាដូចជាពិបាកណាស់។

ដេវ៉ា៖ មាន។ ជាពិសេសនៅរដូវក្តៅ វាក្តៅខ្លាំងនិងពិបាកទ្រាំណាស់ ដូច្នេះក្នុងការងារ ខ្ញុំក៏ប្រុងប្រយ័ត្នដែរ។ សម្លៀកបំពាក់ការងារ មានភ្ជាប់កង្ហារ។ នៅពេលចេញបញ្ជាឲ្យធ្វើការងារបន្ទាប់ ខ្ញុំប្រើភាសាជប៉ុន និងភាសាបាលី(Bali) ដើម្បីមិនឲ្យមានការភាន់ច្រឡំចំពោះប

ញ្ញា។

④ ចុះកន្លែងនៅវិញ មានលក្ខណៈយ៉ាងណាដែរ? តើអ្នកមានទំនាក់ទំនងជាមួយអ្នកនៅក្នុងមូលដ្ឋានដែរឬទេ?

ស៊្វីរីអាណា៖ ពិតជាល្អណាស់។ ខ្ញុំក៏បានធ្វើគារវកិច្ច និងនិយាយគ្នាអំពីភាពខុសគ្នារបស់វប្បធម៌ប្រទេសទាំងពីរផងដែរ ជាមួយលោកយាយម្នាក់ដែលនៅក្បែរកន្លែងស្នាក់នៅ។

ដេវ៉ា៖ នៅបន្ទប់ជួល មានជនជាតិជប៉ុនច្រើន ហើយខ្ញុំតែងតែធ្វើគារវកិច្ចទៅកាន់ពួកគាត់ជានិច្ច។ ហើយខ្ញុំក៏បានចូលរួមក្នុងការសម្អាតទន្លេនៅក្នុងមូលដ្ឋានផងដែរ។

⑤ ហេតុអ្វីបានជាអ្នកមានបំណងចង់យកជំនាញជាក់លាក់កម្រិត2?

ស៊្វីរីអាណា៖ ខ្ញុំមិនដឹងថា10ឆ្នាំខាងមុខ នឹងទៅជាយ៉ាងណាទេ ប៉ុន្តែនៅពេលអនាគត ខ្ញុំចង់ធ្វើការយូរអង្វែង ដោយយកគ្រួសារមកនៅជាមួយ។

ដេវ៉ា៖ ខ្ញុំមានអាយុ31ឆ្នាំហើយ ហើយបើទោះជាខ្ញុំរៀបការ ខ្ញុំនៅតែចង់ធ្វើការយូរអង្វែង។

⑥ តើអ្នកបានប្រឹងប្រែងបែបណាដើម្បីប្រឡងជាប់ជំនាញជាក់លាក់កម្រិត2?

ស៊្វីរីអាណា៖ ខ្ញុំរៀនដោយអានសៀវភៅពុម្ពជាដើមតាមអ៊ីនធើណេត 2ម៉ោងក្នុងមួយថ្ងៃ រយៈពេល2ខែ។ ពាក្យបច្ចេកទេសជាដើម ពិបាកខ្លាំង ហើយខ្ញុំបានប្រឡងជាប់នៅពេលប្រឡងលើកទី3 នៅឆ្នាំទី5ដែលជាឆ្នាំកំណត់សម្រាប់ជំនាញជាក់លាក់។

ដេវ៉ា៖ វាពិបាក ប៉ុន្តែខ្ញុំអាចយល់បានដោយមើលវីដេអូជាដើមជាភាសាជប៉ុន។

⑦ សម្រាប់ជំនាញជាក់លាក់កម្រិត2 តើអ្នកគិតយ៉ាងណាចំពោះរយៈពេលធ្វើការ និងពីអនាគត?

ស៊ូរីអាណា៖ គឺដោយសារខ្ញុំចង់ធ្វើការយូរអង្វែង។ អ្នកផ្សេងដែលធ្វើការនៅទីនេះដែរ ក៏បាននិយាយថា ពួកគេចង់យកជំនាញកម្រិត2 និងធ្វើការយូរអង្វែងផងដែរ។

ដេវ៉ា៖ ខ្ញុំចង់ធ្វើការដូចជាឪពុកម្ដាយរបស់ខ្ញុំដែរ និងចង់ក្លាយជាប្រធានក្រុមហ៊ុនផ្នែកការងារកសិកម្មនៅប្រទេសកំណើតរបស់ខ្ញុំ។

⑧ តើអ្នកមានគោលដៅអ្វីក្នុងពេលអនាគត? តើអ្នកគិតយ៉ាងណាចំពោះអនាគតនៅក្នុងប្រទេសកំណើតរបស់អ្នក?

ស៊ូរីអាណា៖ ឥឡូវនេះ កូនរបស់ខ្ញុំមានអាយុ1ឆ្នាំហើយ ហើយនៅពេលអនាគត ខ្ញុំចង់ហៅគ្រួសាររបស់ខ្ញុំមករស់នៅទីនេះ និងធ្វើការយូរអង្វែងក្នុងប្រទេសជប៉ុន។ នៅកោះបាលី ប្រាក់ចំណូលពីវិស័យកសិកម្ម គឺមានប្រហែល 60 ម៉ឺន យ៉េន ក្នុងមួយឆ្នាំ ហើយខ្ញុំចង់គ្រប់គ្រងដំណើរការវាដោយពង្រីកទ្រង់ទ្រាយឲ្យធំ។

ដេវ៉ា៖ ខ្ញុំមិនទាន់រៀបការនៅឡើយទេ។ ខ្ញុំចង់រៀបការជាមួយមិត្តស្រីរបស់ខ្ញុំនៅប្រទេសកំណើត និងធ្វើការយូរអង្វែងក្នុងប្រទេសជប៉ុន។